# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## គម្រោងសាងសង់
## “ ព្រះពុទ្ធប្បដិមាកម្ពស់ ១០៨ ម៉ែត្រ ”
## នៅលើខ្នងភ្នំបូកគោ ក្នុងឧទ្យានជាតិព្រះមុនីវង្ស បូកគោ ខេត្តកំពត



ក្រុមហ៊ុន សុខា អូតែល ដែលមាន អ្នកឧកញ៉ាបណ្ឌិត **សុខ គង់** ជាប្រធាន បានទទួលការអនុញ្ញាតជា គោលការណ៍ពីរាជរដ្ឋាភិបាលកម្ពុជា តាមរយៈលិខិតលេខ ៧៣០ សជណ.ដប ចុះថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២២ របស់ទីស្ដីការគណៈរដ្ឋមន្ត្រី និងលិខិតលេខ១៥៨០ សជណ.បស្ត ចុះថ្ងៃទី៨ ខែកញ្ញា ឆ្នាំ២០២២ របស់ក្រសួងបរិស្ថាន ឱ្យក្រុមហ៊ុនសាងសង់ព្រះពុទ្ធប្បដិមា កម្ពស់ ១០៨ម៉ែត្រ នៅលើខ្នងភ្នំបូកគោស្ថិតក្នុងភូមិសាស្ត្រវាលស្រែប្រាំរយនៃឧទ្យានជាតិព្រះមុនីវង្ស“បូកគោ”ដែលមានលក្ខណៈនិងរសនិយមជាខ្មែរស្របតាមក្បួនខ្នាត ទំនៀមទម្លាប់ ព្រះពុទ្ធសាសនា និងរចនាប័ទ្មជាតិដែលមានការឯកភាពពីក្រុមការងារអន្តរក្រសួង និងការឯកភាព គាំទ្រពីគណៈសង្ឃនាយកនៃព្រះរាជាណាចក្រកម្ពុជា។

គម្រោងកសាងព្រះពុទ្ធប្បដិមានេះ ជាព្រះពុទ្ធប្បដិមាដែលធំហើយខ្ពស់ជាងគេនៅ ព្រះរាជាណាចក្រកម្ពុជា និងស្ថិតក្នុងចំណោមព្រះពុទ្ធប្បដិមាខ្ពស់ៗនៅលើពិភពលោក ដែលមានទម្រង់ជា ព្រះពុទ្ធមារវិជ័យ ឬ ផ្ចាញ់មារ នៃរចនាប័ទ្មបាយ័ន្ត ដែលជារចនាប័ទ្មកំពូលនៃព្រះពុទ្ធសាសនាក្នុងរជ្ជកាលព្រះបាទជ័យវរ័ន្មទី៧ សតវត្សរ៍ទី១៣។ ព្រះពុទ្ធប្បដិមានេះ នឹងសាងសង់អំពីបេតុងអារម៉េ មានពណ៌មាស បែរព្រះភក្ត្រទៅទិសខាងកើត មានកម្ពស់១០៨ ម៉ែត្រ ពីនីវ៉ូសូន្យនៃខឿនផ្ទាល់ដីដល់កំពូលព្រះមោលី ដែលតំណាងមង្គលទាំង ១០៨ របស់ព្រះអង្គ ទ្រង់គង់ភ្នែន នៅលើបល្ល័ង្កផ្កាឈូករាងរង្វង់(វដ្តសង្ខារ) ដែលទម្រង់ក្បាច់រចនាបល្ល័ង្កនេះ យកលំនាំតាមផ្នែកមួយរបស់ សសរពេជ្រប្រាសាទដំរីក្រាបនៃរចនាប័ទ្មគូលែន ក្នុងរជ្ជកាលព្រះបាទជ័យវរ័ន្មទី២ សតវត្សរ៍ទី៩ ។ ចំពោះខឿន ផ្ទាល់ដី យកលំនាំតាមរចនាប័ទ្មអង្គរវត្ត ក្នុងរាជ្ជកាលព្រះបាទសូរ្យវរ័ន្មទី២ សតវត្សរ៍ទី១២ ។ ចំណែកខឿន ជាន់ទី១ មានក្លោងទ្វារបែនឬ រានហាល នៅចំពីមុខ សម្រាប់ប្រារព្ធពិធីសាសនា ហើយមានព្រះពុទ្ធរូប ៧អង្គ និងព្រះអសីតិសាវ័ក ៥អង្គ សរុបចំនួន ១២អង្គ (តំណាងឲ្យខែឆ្នាំទាំង១២) គង់ក្នុងបុស្បុក តម្កល់ជុំវិញព្រះពុទ្ធប្បដិមាអង្គធំ និងមានជណ្តើរចំនួន៨ (តំណាងទិសទាំង៨ និងអរិយមគ្គទាំង៨) សម្រាប់ឡើងឆ្ពោះទៅកាន់ទីសក្ការៈ នៃព្រះពុទ្ធប្បដិមា។

ជារួមគម្រោងសាងសង់ព្រះពុទ្ធប្បដិមានេះ ជាការរក្សានូវអត្តសញ្ញាណជាតិនៃវប្បធម៌សាសនា ដោយឈរលើមូលដ្ឋានរក្សាចាស់ បង្កើតថ្មី នាសម័យតេជោសុខសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ ហើយព្រះពុទ្ធប្បដិមាអង្គនេះ នឹងគង់នៅជាសម្បត្តិវប្បធម៌សាសនាជាតិ តជំនាន់សម្រាប់ជាទីសក្ការៈ ដ៏ឧដុង្គឧត្តមរបស់ពុទ្ធ សាសនិកជនទាំងអស់គ្នា ជារហូតតរៀងទៅ ។ គម្រោងសាងសង់នេះ នឹងត្រូវចំណាយថវិកាប្រមាណ ៦០ លានដុល្លារអាមេរិក ។

# ប្លង់បង្ហាញទំនាក់ទំនងរវាង
# ប្លង់មេព្រះពុទ្ធប្បដិមាកម្ពស់ ១០៨ម៉ែត្រ និងវត្តព្រះអង្គធំភ្នំបូកគោ








# គម្រោងប្លង់សាងសង់ព្រះពុទ្ធប្បដិមាកម្ពស់ ១០៨ ម៉ែត្រ




# ផែនទីបង្ហាញផ្លូវទៅការដ្ឋានសាងសង់ព្រះពុទ្ធប្បដិមាកម្ពស់ ១០៨ ម៉ែត្រ




1



ផ្លូវចូលឧទ្យានជាតិព្រះមុនីវង្ស " បូកគោ "

2



រូបសំណាកលោកយាយម៉ៅ

3



គម្រោងទី២ " បុរីមរកត ឋានសួគ៌ "

4



សណ្ឋាគារ ឋានសួគ៌ សុខា

5



ស្ថានីយសូគីមិុច " លើភ្នំបូកគោ "

6



វត្តសំពៅប្រាំ

7



ខ្លោងទ្វារមេឃ

8



ព្រះពុទ្ធប្បដិមាកម្ពស់ ១០៨ម៉ែត្រ

# ប្លង់បាត នៃបុស្បុកទាំង១២ ជុំវិញព្រះពុទ្ធបដិមាកម្ពស់ ១០៨ម៉ែត្រ










សម្រាប់ព័ត៌មានបន្ថែម

សូមស្កេនទីនេះ

## បុស្បុកតម្កល់ ព្រះទាំង១២ ជុំវិញព្រះពុទ្ធបដិមាកម្ពស់ ១០៨ម៉ែត្រ

■ បានជាវហើយ ■ មិនទាន់ជាវ


① ព្រះពុទ្ធប្រទានអភ័យ


② ព្រះពុទ្ធសមាធិ


③ ព្រះពុទ្ធសម្តែងធម្មចក្រ


④ ព្រះសារីបុត្រ


⑤ ព្រះមហាកស្សប


⑥ ព្រះអង្គុលិមាល


⑦ ព្រះអង្គចម


⑧ ព្រះសីវលី


⑨ ព្រះមហាមោគ្គលាន


⑩ ព្រះអានន្ទ


⑪ ព្រះពុទ្ធប្រក់នាគ


⑫ ព្រះពុទ្ធប្រទានពរ

# រូបភាព 3D នៃព្រះពុទ្ធបដិមាអង្គតូច ៨៤,០០០អង្គ










ខ្នាតព្រះពុទ្ធបដិមាអង្គតូច




ខ្នាតព្រះពុទ្ធបដិមា ៩២អង្គ



- ថ្នាក់ទី១ : តម្លៃ ១,១០៨ ដុល្លារអាមេរិក ក្នុង ១ អង្គ
- ថ្នាក់ទី២ : តម្លៃ ៨៨៨ ដុល្លារអាមេរិក ក្នុង ១ អង្គ
- ថ្នាក់ទី៣ : តម្លៃ ៦៨៨ ដុល្លារអាមេរិក ក្នុង ១ អង្គ
- ថ្នាក់ទី៤ : តម្លៃ ២៦៨ ដុល្លារអាមេរិក ក្នុង ១ អង្គ

# ទីតាំងចារឹកឈ្មោះសប្បុរសជនចូលបច្ច័យកសាង
# " ព្រះពុទ្ធបដិមាកម្ពស់ ១០៨ ម៉ែត្រ "
# នៅលើខ្នងភ្នំបូកគោ ក្នុងឧទ្យានជាតិព្រះមុនីវង្ស បូកគោ ខេត្តកំពត




១. ទីតាំងនៅសង្ខាងជណ្តើរទិសខាងលិច សម្រាប់ចារឹកឈ្មោះសប្បុរសជន ដែលបានចូលបច្ច័យ ចាប់ពី ១០,០០០ដុល្លារ ឡើងទៅ

២. ទីតាំងនៅសង្ខាងជណ្តើរទិសខាងត្បូង សម្រាប់ចារឹកឈ្មោះសប្បុរសជន ដែលបានចូលបច្ច័យ ចាប់ពី ៣០,០០០ដុល្លារ ឡើងទៅ

៣. ទីតាំងនៅសង្ខាងជណ្តើរទិសខាងជើង សម្រាប់ចារឹកឈ្មោះសប្បុរសជន ដែលបានចូលបច្ច័យ ចាប់ពី ៥០,០០០ដុល្លារ ឡើងទៅ

៤. ទីតាំងនៅសង្ខាងជណ្តើរទិសខាងកើត សម្រាប់ចារឹកឈ្មោះសប្បុរសជន ដែលបានចូលបច្ច័យ ចាប់ពី ១០០,០០០ដុល្លារ ឡើងទៅ ។




ពុទ្ធបរិស័ទមានសទ្ធាជ្រះថ្លា ចង់ភ្ជាប់និស្ស័យកសាងព្រះពុទ្ធបដិមា
ដ៏ស្កឹមស្កៃនេះអាចចូលរួមជាបច្ច័យ និងទទួលយកកុសលផលបុណ្យតាមសទ្ធារៀងៗខ្លួន

**ក្រុមហ៊ុន សុខា អូតែល**
SOKHA HOTEL CO., LTD

ទូរស័ព្ទទទួលបច្ច័យ៖
085 430 999 | 097 430 9999

ទូរស័ព្ទទំនាក់ទំនង៖
031 7777 108 | 014 777 108 | 015 777 108

**ធនាគារ ACLEDA**
SOKHA HOTEL CO., LTD.
(PREAH PUTH PADIMA 108M-ON BOKOR)
0001-08108108-99 (KHR) 0001-08108108-88 (USD)

**ធនាគារ ABA**
SOKHA HOTEL CO., LTD.
(PREAH PUTH PADIMA 108M-ON BOKOR)
106 108 108 (KHR) 107 108 108 (USD)

Preahputhpadima108monbokor | Preahputhpadima108monbokor | ព្រះពុទ្ធបដិមាកម្ពស់១០៨ម | Preahputhpadima108monbokor.com